មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0084**

# សម្ភាសន៍ជាមួយឈ្មោះ សុន ធឿង ភេទប្រុស អាយុ៧២ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ អ្នកនេសាទ

## សព្វថ្ងៃរស់នៅភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ហ៊ិន សុធានី

## ០០:២៨:២៣

## ១៩ទំព័រ

ធានី : ថ្ងៃហ្នឹងទី៧ ខែធ្នូ ឆ្នាំ២០១០ ។ ពួកខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយពួកខ្ញុំចុះមកនេះ គ្រាន់ចង់សាកសួរអ៊ំទាក់ទងនឹងប្រវត្តិរបស់អ៊ំ កាលសម័យដូចជាការរស់នៅរបស់អ៊ំតាំងពីក្មេងរហូតមកដល់សព្វថ្ងៃនឹង តើអ៊ំបានឆ្លងកាត់ប្រទះអីខ្លះ ។ ហើយប្រវត្តិទាំងនេះ ពួកខ្ញុំសុំអនុញ្ញាតិយកទៅធ្វើជាសៀវភៅ ក៏ដូចជាចុះនៅក្នុងទស្សនាវដ្ដីស្វែងរកការពិតប្អុក៏ចុះនៅ សម្រាប់ឲ្យក្មេងៗក្រោយបានរៀន ក៏ដូចជាអ្នកស្រាវជ្រាវផ្សេងគាត់ចង់ដឹងប្រវត្តិអ្នកភូមិ យើងនេះម៉េចដែរ ។ ម៉េចដែរ អ៊ំអត់យល់ទាស់អីទេ?

ធឿង : ទេ! វាមានទាស់អី ។

ធានី : ចឹងអ៊ំខ្ញុំសុំថតជាសម្លេង ក៏ដូចជាថតជារូបថតអីបានទេ?

ធឿង : មានអី ថតទៅ ។

ធានី : អ៊ំមានឈ្មោះអី?

ធឿង : ធឿង សុន ធឿង ។

ធានី : ឈ្មោះអីគេធឿង?

ធឿង : ឪខ្ញុំឈ្មោះ សុន ។

ធានី : សុន ធឿង?

ធឿង : ធឿង ។

ធានី : ធឿង?

ធឿង : បាទ!

ធានី : ឆ្នាំហ្នឹងអ៊ំអាយុប៉ុន្មានហើយ?

ធឿង : ៧១ អឺ!៧២ហើយ ។

ធានី ៈ  អ៊ំមានស្រុកកំណើតនៅណាដែរ?

ថឿន ៈ  នៅនឹងផ្កាំនេះឯង ។

ធានី ៈ  នៅៗ?

ថឿន ៈ  ភូមិផ្កាំនេះឯង ។

ធានី ៈ  នៅភូមិផ្កាំ ឃុំអីដែរ?

ថឿន ៈ  ឃុំផ្កាំ ភូមិផ្កាំ ។

ធានី ៈ  ស្រុកអីគេទៅ?

ថឿន ៈ  ស្រុកស្វាយចេក ។

ធានី ៈ  ខេត្តអីគេ?

ថឿន ៈ  ខេត្តបន្ទាយមានជ័យនេះឯង ។

ធានី ៈ  ដល់ពេលសព្វថ្ងៃអ៊ំរស់នៅកន្លែងណាដែរ?

ថឿន ៈ  នៅនោះ ភូមិផ្កាំនេះឯង ។

ធានី ៈ  សព្វថ្ងៃក៏រស់នៅស្រុកកំណើតដែរ?

ថឿន ៈ  បាទ!

ធានី ៈ  ឪពុកអ៊ំឈ្មោះអីដែរ?

ថឿន ៈ  ឈ្មោះ សុន ។

ធានី ៈ  អីគេសុន?

ថឿន ៈ  អឺ!

ធានី ៈ  ជីតាគាត់ឈ្មោះអីគេ?

ថឿន ៈ  មាសៗ សុន ។

ធានី ៈ  មាគ សុន?

ថឿន ៈ  មាស!

ធានី ៈ  មាស?

ថឿន ៈ  ហ្នឹងហើយ ។

ធានី ៈ  គាត់នៅរស់ ឬក៏នេះហើយ?

ថឿន ៈ  អត់ ។

ធានី ៈ  ស្លាប់ហើយ?

ធឿន ៖ ស្លាប់ហើយ ។

ធានី ៖ ស្លាប់ពេលណាដែរ?

ធឿន ៖ អូ! យូរហើយ ។

ធានី ៖ ស្លាប់សម័យណា?

ធឿន ៖ សម័យឥស្សរ ។

ធានី ៖ សម័យឥស្សរៈ ឆ្នាំណាទៅ?

ធឿន ៖ អូ! មិនដឹងទេ មិនយល់ទេ ។

ធានី ៖ ចុះម្តាយអ៊ំ?

ធឿន ៖ ម្តាយឈ្មោះ ឡូត លឹម ។

ធានី ៖ ឡូត លឹម?

ធឿន ៖ អឺ!

ធានី ៖ លីន ឬក៏លឹម?

ធឿន ៖ លឹម ។

ធានី ៖ លឹម?

ធឿន ៖ អឺ! ឡូត លឹម ។

ធានី ៖ ឡូត លឹម?

ធឿន ៖ នោះហើយ ។

ធានី ៖ គាត់នៅរស់ទេ?

ធឿន ៖ អត់ ។

ធានី ៖ ស្លាប់ពេលណាដែរ?

ធឿន ៖ សម័យប៉ុលពត ។

ធានី ៖ ស្លាប់ដោយសារអីគេដែរ?

ធឿន ៖ អត់បាយ ។

ធានី ៖ អត់បាយហ៎ ។ នៅណាវិញ គាត់ស្លាប់នៅណា?

ធឿន ៖ នៅនេះឯង ។

ធានី ៖ នៅភូមិយើង?

ធឿន ៖ បាទ!

ធានី ៖ អ៊ំមានបងប្អូនប៉ុន្មាននាក់?

ធឿង ៖ នែក! ឈ្មោះមានបងប្អូន៦នាក់ ។

ធានី ៖ បងប្អូន៦នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ធឿង ៖ ប្រុសតែ២ ស្រី៤ ប្រុស២ ។

ធានី ៖ គាត់នៅរស់ទាំងអស់ទេ?

ធឿង ៖ នៅរស់ នៅបងមួយនៅភូមិគោកដូ ។

ធានី ៖ ភូមិអីគេ?

ធឿង ៖ ភូមិគោកដូ យើង ។

ធានី ៖ គោកដូ?

ធឿង ៖ បាទ! នៅឃុំកាស ។

ធានី ៖ ចឹងក្រៅពីហ្នឹងគាត់ស្លាប់អស់ហើយ?

ធឿង ៖ ស្លាប់អស់ហើយ ។

ធានី ៖ ដោយសារអីគេ អ៊ំដឹងទេ?

ធឿង ៖ ស្លាប់នឹងសម័យហ្នឹងឯង សម័យប៉ុលពត ។

ធានី ៖ សម័យប៉ុលពត?

ធឿង ៖ អឺ!

ធានី ៖ ចឹងនៅបងមួយ បងស្រី បងប្រុស?

ធឿង ៖ បងស្រី ។

ធានី ៖ បងស្រី ។ ចឹងស្លាប់ស្រី៣ ប្រុសមួយ?

ធឿង ៖ អឺ!

ធានី ៖ នៅសល់តែអ៊ំមួយ ហើយនឹងនោះមួយទេ?

ធឿង ៖ សល់ អឺ!ស្រី២ ។

ធានី ៖ ស្រី២?

ធឿង ៖ អឺ!

ធានី ៖ សល់ស្រី២ ។ ហើយអ៊ំជាកូនទីប៉ុន្មានដែរនៅក្នុងគ្រួសារ?

ធឿង ៖ អឺ! កូនទី៣ហើយ ។

ធានី ៖ ពួកគាត់ស្លាប់នឹងកាលស្លាប់នៅសម័យប៉ុលពត?

ថឿង : បាទ! សម័យប៉ុលពត ។

ធានី : ដោយសារអីដែរអ៊ំ?

ថឿង : ដោយសារអត់បាយហ្នឹង ។

ធានី : នៅភូមិយើងដែរ?

ថឿង : បាទ!

ធានី : អូ!ចឹងនៅភូមិយើងអត់បាយច្រើននាក់?

ថឿង : អូ! អត់បាយឡើងម៉ាចំនួន ម៉ាកន្ទុក់ម៉ាវែកគ្នា១០នាក់នោះ អត់បាយវាមិនចំកន្ទុក់ម៉ាវែក ំនួននែក!១០នាក់ណា ។

ធានី : ចឹងអ៊ំមានបានរៀនបានអីទេ?

ថឿង : រៀន ។

ធានី : រៀនថ្នាក់ទីប៉ុន្មានដែរ?

ថឿង : ថ្នាក់ទី៩ចាស់ ។

ធានី : រៀនទី៩ចាស់ ។ នៅណាវិញ រៀននៅសាលាណាដែរ?

ថឿង : នៅសាលាផ្កាំនេះឯង សម័យបង្រៀនខ្ញុំ រៀនសម័យឥស្សរៈ ។

ធានី : សាលាផ្កាំ ឬអនុវិទ្យាល័យ?

ថឿង : ថាត្រឹម ។

ធានី : សាលាផ្កាំត្រឹមបឋមនឹង?

ថឿង : អូ! រៀនជាមួយជំនាន់ឥស្សរៈនឹង មិនដឹងជា ។

ធានី : មិនដឹងជាម៉េចអ៊ំ?

ថឿង : មិនដឹងជាថ្នាក់អីទេ ចេះរៀនហៅថាពីដើមមិញវាចូលវចនដ្ឋានដឹងស្អី ។

ធានី : ប៉ុន្តែហៅទី៩ទៅ?

ថឿង : ហ្នឹងហើយទី៩ ។

ធានី : ចឹងម៉េចទៀតអ៊ំ អ៊ំចូលរៀនហើយម៉េចបានអ៊ំឈប់រៀន?

ថឿង : នែក! បួសៗ ។

ធានី : បួសនៅណាវិញ?

ថឿង : បួសនៅផ្កាំនេះឯង ។

ធានី : នៅផ្កាំ នៅវត្តអីគេ?

ចឿង ៖  នៅវត្តៗប្រាសាទ កោះភ្នំផ្តាំនេះឯង ។

ធានី ៖  បួសនៅវត្តប្រាសាទ បួសឆ្នាំប៉ុន្មានចាំទេ?

ចឿង ៖  អូ! អត់ចាំទេ យ៉ាង ។

ធានី ៖  វត្តប្រាសាទអីគេ?

ចឿង ៖  ប្រាសាទកោះភ្នំផ្តាំ ។

ធានី ៖  ប្រាសាទកោះភ្នំផ្តាំ?

ចឿង ៖  អឺ!

ធានី ៖  នៅក្នុងភូមិផ្តាំយើងដែរ?

ចឿង ៖  បាទ!

ធានី ៖  អ៊ំបួសបានប៉ុន្មានវស្សាដែរ?

ចឿង ៖  បាន៧វស្សាហើយ ។

ធានី ៖  បួសបានយូរណាស់ ។ បួស៧វស្សា ។ ក្រោយពីបួសទៅណាទៀតអ៊ំ?

ចឿង ៖  បួសមក សឹកមកក៏បានយាយនេះឯង ។

ធានី ៖  រៀបគ្រួសារឆ្នាំប៉ុន្មាន អ៊ំចាំទេ?

ចឿង ៖  អូ! ខ្ញុំដូចមិនសូវចាំដែរ ។

ធានី ៖  កាលហ្នឹងអាយុប៉ុន្មានអ៊ំរៀបការ?

ចឿង ៖  អាយុ៣មើលៗបាន ២៩បានប្រពន្ធ ។

ធានី ៖  ២៩?

ចឿង ៖  អឺ!

ធានី ៖  អ៊ំស្រីការហ្នឹងរៀនគ្រួសារអាយុប៉ុន្មាន?

ប្រពន្ធ ៖  ១៩ ។

ធានី ៖  អ៊ំស្រី១៩ អ៊ំប្រុស២៩ ចឹងមែន?

ប្រពន្ធ ៖  មិនមែន១៩ទេ ។

ចឿង ៖  មិនដឹងទេ ។

ធានី ៖  ចឹងគ្រួសារអ៊ំឈ្មោះអី?

ចឿង ៖  នែក! នឿន ។

ធានី ៖  អីគេនឿន?

ថឿង ៖ ឆូវ នឿន។

ធានី ៖ ឆូវ នឿន។

ថឿង ៖ នឿនៗ ។

ធានី ៖ មានកូនប៉ុន្មាននាក់ហើយ?

ថឿង ៖ កូន៨ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ប្រពន្ធ ៖ នៅសល់៨សព្វថ្ងៃ។

ធានី ៖ ចាំ!

ថឿង ៖ ទេ! ងាប់មួយ ។

ធានី ៖ អូ! តាមពិត៩?

ប្រពន្ធ ៖ ចាំ! ៩ ស្លាប់មួយកាលពីសម័យនោះ ។

ធានី ៖ ចឹងស្រីប៉ុន្មាន ប្រុសប៉ុន្មាន៩នាក់ហ្នឹង?

ថឿង ៖ ហ្នឹងនៅសល់ស្រី៤ ប្រុស៤ ។

ធានី ៖ ចឹងស្លាប់កូនស្រី កូនប្រុស?

ថឿង ៖ ប្រុស ។

ធានី ៖ ស្លាប់ប្រុសមួយ ចឹងស្រី៤ ប្រុស៤នៅសល់?

ថឿង ៖ អឺ!

ធានី ៖ ស្រី៤ ស្លាប់មួយនៅសល់៤ស្មើៗ ស្លាប់ដោយសារអីដែរ អ៊ំកាលនឹងកូន?

ថឿង ៖ នៅនោះសម័យប៉ុលពត ។

ធានី ៖ គាត់កើតសម័យនឹង ឬក៏?

ថឿង ៖ សម័យប៉ុលពតអត់បាយ ។

ប្រពន្ធ ៖ កើតបានម៉ាខួប ដាងម៉ាខួប ស្លាប់ ។

ធានី ៖ អត់បាយ?

ថឿង ៖ អត់បាយ ។

ប្រពន្ធ ៖ អត់បាយ ខ្ញុំគេប្រើឲ្យទៅធ្វើការ ទុកកូនឲ្យបងមើល នេះគេបានអីស៊ីណាំ ។

ថឿង ៖ ហើយក៏ងាប់ទៅ ។

ធានី ៖ ម៉េចទៀតអ៊ំ ក្រោយពីរៀបគ្រួសារហើយ អ៊ំទៅណា ធ្វើអីខ្លះ អ៊ំជួយរៀបរាប់បានទេ តាំងពីពេលហ្នឹងរហូតមកដល់ឥឡូវ?

ថឿង ៖ ខ្ញុំនោះ សម័យប៉ុលពត គេឲ្យរកតែត្រីនេះឯង គេឲ្យនេសាទត្រីទាំងអស់ ។

ធានី ៖ រកត្រីនៅណាវិញ?

ថឿង ៖ នៅ ភូមិអាងតាម៉េងយើង ។

ធានី ៖ អាងតាម៉េង រកត្រីនៅអាងតាម៉េង?

ថឿង ៖ ហ្នឹងហើយ ។

ធានី ៖ ហើយពីនឹងទៅដល់អាងតាម៉េងនឹង ប៉ុន្មានគីឡូទៅ?

ថឿង ៖ ៣គីឡូ ។

ធានី ៖ ៨គីឡូ?

ថឿង ៖ ៣ៗគីឡូ គេឲ្យទៅមុជទឹកនឹងឯង ។

ធានី ៖ ចុះអ៊ំអាចជួយរៀបរាប់ទេ ថាកាលដំបូងមកម៉េចបាននៅភូមិយើង ខ្មែរក្រហមមកកាន់កាប់យ៉ាងម៉េច កកើតឡើងយ៉ាងម៉េចអ៊ំអាចជួយរៀបរាប់បានទេ ដូចថាកាលហ្នឹងអ៊ំមិនធ្លាប់រៀបគ្រួសារៗហើយដូចថាយើងនៅផ្ទះ នៅធ្វើស្រែចំការបានប៉ុន្មានឆ្នាំ បានចាប់ផ្តើមមានខ្មែរកហមមានអីចូលក្នុងភូមិយើង ហើយបានឲ្យអ៊ំធ្វើការផ្សេងៗ?

ថឿង ៖ ខ្ញុំធ្វើស្រែបានៗ៣ឆ្នាំ បានប្រពន្ធ ធ្វើស្រែបាន៤ឆ្នាំៗ មកចាប់ផ្តើមសម័យប៉ុលពតនេះ ។

ធានី ៖ ម៉េចទៀតអ៊ំ?

ថឿង ៖ ដល់សម័យប៉ុលពតនេះ ។

ធានី ៖ ដូចថាសម័យប៉ុលពតនឹង គេធ្វើម៉េចខ្លះ ចូលភូមិនឹងបានអ៊ំថាសម័យនឹងជាសម័យប៉ុលពតដំបូងមានអ្នកណាគេចូលមកប្រាប់ អ្នកណាគេធ្វើអីចឹងៗ?

ប្រពន្ធ ៖ គេមកគេមិននេះផង គេមកបាញ់គ្នាផ្ទុងផាំងៗគេជម្លៀសទៅនោះ ជម្លៀសទៅនេះ ជម្លៀសនៅណា ។ ជម្លៀសចេញពីភូមិរត់ចេញពីភូមិ ។

ថឿង ៖ ជម្លៀសអស់ ។

ប្រពន្ធ ៖ ខ្ញុំក៏រត់ទៅថ្មពួកទៅនៅថ្មពួក ។

ធានី ៖ ចឹងអ៊ំបានរត់ចេញពីនេះដែរ?

ថឿង ៖ បាទ! រត់អស់ ។

ប្រពន្ធ ៖ គ្មានអ្នកណានៅទេ ក្នុងភូមិនេះ ។

ធានី ៖ ចឹបានរត់ចឹងអ៊ំ?

ធឿង ៖ គេបាញ់ ។

ធានី ៖ គេបាញ់គ្នា គេបាញ់រវាងអ្នកណានិងអ្នកណា?

ធឿង ៖ ថានៅយួន អឺ!បាញ់នឹងខ្មែរ ទាហានយើង ។

ធានី ៖ ជាមួយអ្នកណា?

ធឿង ៖ ទាហានយើងនឹង ។

ប្រពន្ធ ៖ ខ្មែរក្រហម ។

ធានី ៖ ទាហានយើងជាមួយទាហាន?

ធឿង ៖ ខ្មែរក្រហម ។

ធានី ៖ ទាហានខ្មែរក្រហមមកពីខាងណាវិញ ពេលនឹង?

ធឿង ៖ ខ្មែរក្រហមនឹង ដឹងមកពីកើតនេះមក មិនដឹងមកពីខាងណា ។

ធានី ៖ ចឹងនៅស្រុកភូមិយើងអត់មានខ្មែរក្រហមដែលគេចូលបដិវត្តទេ?

ធឿង ៖ អត់ទេ ។

ធានី ៖ អត់មាន?

ធឿង ៖ អត់ទេ ។

ធានី ៖ ចឹងស្រុកយើងកាលពេលនឹងនៅជាមួយនឹង ។ កាលពេលនឹងបែកសម័យលន់ នល់នៅ?

ធឿង ៖ នៅសម័យលន់ នល់នោះឯង ។

ធានី ៖ នៅក្នុងសម័យលន់ នល់?

ធឿង ៖ សម័យលន់ នល់នឹង គេបាញ់ទាហានលន់ នល់ ។

ធានី ៖ ចុះគេមានឃោសនា កាលនៅភូមិយើងមានឃោសនាចូលបដិវត្ត ចូលអីមានទេ?

ប្រពន្ធ ៖ ដូចអត់មាន ។

ធានី ៖ នៅភូមិនេះអត់មានទេ យើងនៅខាងលន់ នល់រហូតដល់បែកលន់ នល់ ខ្មែរក្រហមចូលមក?

ធឿង ៖ បាទ! ខ្មែរក្រហមចូលមក ។

ធានី ៖ ហើយពេលចូលមកដល់យ៉ាងម៉េចទៅអ៊ំ ពេលនឹងអ៊ំមិនរត់ត្រឡប់មកភូមិយើងវិញ?

ធឿង ៖ នៅថ្មពួកម៉ាៗឆ្នាំ ។

ធានី ៖ បានត្រឡប់មកនេះវិញ?

ថឿង ៖ បាទ!

ធានី ៖ ហើយមកដល់នេះវិញម៉េចដែរ ឃើញទិដ្ឋភាពនៅក្នុងភូមិ មានប្រជាជនរស់នៅដែរ?

ថឿង ៖ ដល់នេះ ដល់យួនមកបាន អឺ!មិនមែនយួនមក ។

ធានី ៖ កាលពេលអ៊ំមកដល់ភូមិនេះម៉េចទៅ ពេលអ៊ំថារត់ពីថ្មពួកមកយើងនេះវិញ ពេលហ្នឹងភូមិយើងមានអ្នកណាគេគ្រប់គ្រងនៅ ហើយការរស់នៅយ៉ាងម៉េចដែរ ហូបចុកអីម៉េច?

ថឿង ៖ អឺ! កម្មមែនទែន ។

ធានី ៖ កម្មយ៉ាងម៉េចខ្លះអ៊ំជួយប្រាប់បានទេ?

ថឿង ៖ នែក! គ្រាន់តែនៅក្នុងភូមិយើងនេះហើយ យួនចូលមកដល់ហើយនេះ បាញ់ក្នុងភូមិឆ្នាំនេះ ៨៣ដង ដែលបាញ់គ្នា ។

ប្រពន្ធ ៖ ចាប់គានេះចង់ ខ្ញុំទៅរកប្រាក់ៗគេទម្រាំបាន វាយក១០០០ កាលនោះម្នាក់១០០០...ប៉ុនបានឲ្យវា៥០០ បានៗចេះឯង ។

ធានី ៖ ថីបានគេចាប់គា?

ថឿង ៖ នែក!គេចាប់យកប្រាក់ ។

ប្រពន្ធ ៖ គេចាប់ប្រាក់ រកប្រាក់មិនបានគេចងអូសក្រោយរថក្រោះ ហើយខ្ញុំក៏យំដងអីដង ដើររកប្រាក់គេ ។

ធានី ៖ គេអត់មានប្រាប់ថាម៉េចបាននេះ គ្រាន់គេចង់ចាប់យកប្រាក់តែប៉ុណ្ណឹង ។

ប្រពន្ធ ៖ ថីមិនដឹងវាយកប្រាក់ធ្វើអី ។

ធានី ៖ រកតែអ៊ំម្នាក់ឯងទេ ឬក៏អ្នកផ្សេងចឹងដែរ?

ថឿង ៖ តែឯងមួយ ។

ប្រពន្ធ ៖ តែឯង ។

ធានី ៖ អ្នកផ្សេងនៅភូមិនឹងអត់អីទេ?

ថឿង ៖ អ្នកផ្សេង ដែលនៅជិតនឹងមិនអីទេ ។

ធានី ៖ គេអត់មានប្រាប់ពីមូលហេតុអ៊ំនោះ?

ថឿង ៖ ទេ! វាចង់បានប្រាក់យកទៅ រថក្រោះមកវាលេងបៀរអាពួកនឹង នេះវាយកប្រាក់ទៅលេងបៀរ វាចាប់មនុស្ស ។

ធានី ៖ ខាងណាអ្នកចាប់ យួនអ្នកចាប់?

ប្រពន្ធ ៖ យួន ។

ធានី ៖ បន្ទាប់មកទៀតម៉េចអ៊ំ?

ធឿង ៖ មិនដឹងទេ ។

ធានី ៖ ចឹងអ៊ំចង់សួរអ៊ំថា ពេលដែលគេឲ្យរកនេសាត្រី គេឲ្យរកត្រី ខាងណាអ្នកឲ្យអ៊ំជាអ្នករកត្រី?

ធឿង ៖ ខាងសម័យនោះឯង សម័យប៉ុលពត ។

ធានី ៖ ឈ្មោះអី ស្គាល់ឈ្មោះគាត់ ដែលគាត់ចាត់តាំងឲ្យជាអ្នករកត្រី?

ធឿង ៖ ហ៎! គាត់ឈ្មោះ នឿម ។

ធានី ៖ នឿមៗជាអ្នកណាគេ?

ធឿង ៖ ប្រធានប៉ុលពត ។

ធានី ៖ ជាប្រធានខាងនេសាទនឹង?

ធឿង ៖ មិនមែនប្រធានទេ ប្រធាននៅសហករណ៍យើងនេះ ។

ធានី ៖ ប្រធានសហករណ៍?

ធឿង ៖ ហ្នឹង នឿម ។

ធានី ៖ ប្រធានសហករណ៍ៗហ្នឹង គេហៅសហករណ៍អីគេ?

ធឿង ៖ សហករណ៍ផ្កាំនឹងឯង ។

ធានី ៖ សហករណ៍ផ្កាំ?

ធឿង ៖ បាទ!

ធានី ៖ ចឹងនៅសហករណ៍ផ្កាំនឹង ឈ្មោះនឿមនឹងអ្នកចាត់តាំងឲ្យអ៊ំទៅរកត្រី?

ធឿង ៖ ហ្នឹងហើយ ចឹង ។

ធានី ៖ ដល់ពេលអ៊ំស្រីធ្វើការអីគេ?

ធឿង ៖ អឺ! កិនស្រូវ ។

ធានី ៖ កិនស្រូវ ហើយនឿមនឹងអ្នកចាត់តាំងដែរ?

ធឿង ៖ ហ្នឹងហើយ ។

ធានី ៖ ដល់ពេលកូនអ៊ំត្រូវគេយកទៅដាក់សហករណ៍ទាំងអស់?

ធឿង ៖ ហ្នឹងហើយ ។

ធានី ៖ ដាក់នៅកងកុមារចឹង?

ធឿង ៖ កងកុមារទៅនោះ ទៅនៅតាម៉េងនោះឯង ។

ធានី ៖ ហើយដល់កូនដែកបានម៉ាខួបនឹងទៅនៅការដ្ឋាន?

ចឿន ៖ ទេ! នៅភូមិនេះឯង ។

ធានី ៖ តែមានគេមើលផ្សេងទៀត អ្នកមើលកូនអ៊ំ?

ប្រពន្ធ ៖ អត់មានទេ ។

ធានី ៖ ចុះអ៊ំថាឲ្យអ្នកណាបងមើលនោះ?

ប្រពន្ធ ៖ បងៗវានោះ ។

ចឿន ៖ មីងបង ។

ប្រពន្ធ ៖ មីងបងគេ កូនទី១ ។

ធានី ៖ ចុះក្រែងថាបងគេ ត្រូវដឹកហើយ មានពេលណាមើលប្អូន?

ចឿន ៖ នោះហើយបានវាមិនរស់ ទីណាត់ទីណែង ។

ធានី ៖ បងគេអាយុប៉ុន្មាន កូនអ៊ំ?

ចឿន ៖ អាយុ៣០ ។

ធានី ៖ អត់ទេ ចង់និយាយថាកាលសម័យខ្មែរក្រហមនឹង អាយុប៉ុន្មានបានគេឲ្យទៅដឹកអាងតាម៉េច?

ចឿន ៖ អូ! ១២ ១៣នឹងឯង ។

ធានី ៖ ហើយកាលនឹងអ៊ំអត់អាចមើលកូនខ្លួនឯងបានទេ ត្រូវឲ្យកូនមើល?

ប្រពន្ធ ៖ ចុះបើគេឲ្យខ្ញុំទៅចល័ត ទៅច្រូតស្រូវ ស្រុកចែងឲ្យមីងបងគេនៅមើល ។

ធានី ៖ ច្រូតនៅណាវិញ?

ចឿន ៖ ស្រុកចែង ។

ធានី ៖ ស្រុកព្រៃ?

ចឿន ៖ ស្រុកចែង ។

ធានី ៖ ស្រុកចែង?

ចឿន ៖ អឺ!

ប្រពន្ធ ៖ ស្រុកចែងព្រៃ ទៅនៅដេកនោះ ។

ធានី ៖ ចែងព្រៃ?

ប្រពន្ធ ៖ ចាំ! ទៅដេកច្រូតស្រូវនោះ គេយក ។

ធានី ៖ ដល់ពេលមកវិញប្អូនស្លាប់ទៅ?

ប្រពន្ធ ៖ មកវិញក៏វាឈឺទៅ ។

ធានី ៖ ចុះអ៊ំប្រុសទៅនេសាទរហូត?

ថឿន ៖ អឺ! នៅនេសាទ ។

ធានី ៖ ចុះអត់ដែលបានជួបគ្នាទេ គ្រួសារអី?

ថឿន ៖ អូ!

ធានី ៖ ទាំងកូនទាំងប្រពន្ធ?

ថឿន ៖ អឺ! នោះហើយ បែកបាក់គ្នា បែកបាក់គ្នារហូត ។

ធានី ៖ ចឹងអ៊ីកាលពេលអ៊ំនៅនេសាទហ្នឹង អ៊ំធ្វើជាអីគេដែរ មានងារជាអីដែរ?

ថឿន ៖ ហ៊ឺ! ងារអីទេ ទៅបង់ទៅជាមួយបងខ្ញុំ ។

ធានី ៖ តែម្នាក់ឯងទេ?

ថឿន ៖ ទេ! ច្រើនណាស់ ទាំងឪក្មេកអីខ្ញុំទៅទាំងអស់ ។

ធានី ៖ អូ! ឪក្មេកអ៊ំទៅដែរ?

ថឿន ៖ នោះឯង ទាំងឪក្មេក ទាំងបងប្អូនជីដូនមួយផង ។

ធានី ៖ ទាំងប៉ុន្មាននាក់ហ្នឹងអ្នកណាគេធ្វើប្រធាន?

ថឿន ៖ ម៉ាក្រុមបងប្អូនខ្ញុំ ។

ធានី ៖ អូ! បងប្អូនអ៊ំ អ្នកណាគេខ្លះដែលទៅស្គាល់ឈ្មោះគាត់?

ថឿន ៖ នែក! ឪក្មេកខ្ញុំមួយ ឪក្មេក ។

ធានី ៖ ឈ្មោះអីគេគាត់?

ថឿន ៖ ម៉ានែក! តាឆៅនោះ ។

ធានី ៖ តាឆៅ ណាទៀត ។ អ្នកណាគេទៀត?

ថឿន ៖ អ្នកណាទៀត នែកៗតាដាម អ៊ុច ដាម ។

ធានី ៖ អ៊ុច ដាម អ្នកណាគេ?

ថឿន ៖ បងខ្ញុំ ។

ធានី ៖ បងបង្កើត?

ថឿន ៖ ទេ! បងជីដូនមួយ ។

ធានី ៖ បងស្រីប្រុស?

ថឿន ៖ ប្រុស ។

ធានី ៖ អ្នកណាគេទៀត?

ថឿន ៖ នែក! ឃុន ។

ធានី ៖ តាយុននឹងត្រូវជាអីនឹងអ៊ំ?

ធឿង ៖ ត្រូវជាឪពុកមា ។

ធានី ៖ អ្នកណាគេទៀត?

ធឿង ៖ នែក! តាឆែប១បងគេ ។

ធានី ៖ បងបង្កើត?

ធឿង ៖ ទេ! បងជីដូនមួយនោះឯង ។

ធានី ៖ តាឆែប ។

ធឿង ៖ អឺ!

ធានី ៖ បងប្រុស?

ធឿង ៖ បងប្រុស ។

ធានី ៖ អ្នកណាគេទៀតទៅ?

ធឿង ៖ មាននេះមួយឈ្មោះ ឡាម ។

ធានី ៖ អីគេឡាម?

ធឿង ៖ ស្តី រោម ឡាមមួយ ។

ធានី ៖ ឡោម?

ធឿង ៖ រោម ឡាម ។

ធានី ៖ រោម?

ធឿង ៖ រោម១ ។

ធានី ៖ គាត់នឹងជា ត្រូវជាអីនឹងអ៊ំ?

ធឿង ៖ ទេ! មិន គេអ្នកឆ្ងាយ ។

ធានី ៖ អ្នកជិតខាង?

ធឿង ៖ បាទ!

ធានី ៖ តែប៉ុននឹងអ្នកទេ?

ធឿង ៖ បាទ១ ។

ធានី ៖ ៤-៥នាក់ ហើយអ៊ំ ក្នុងចំណោម៤-៥នាក់នឹង អ្នកណាជាប្រធាននេសាទនឹង?

ធឿង ៖ នែក! បងថាម ។

ធានី ៖ ថាមនឹងជាប្រធាននេសាទ?

ចឿង ៖ អឺ!

ធានី ៖ ប្រធានកងនេសាទចឹង?

ចឿង ៖ បាទ!

ធានី ៖ ចុះអ៊ំមាននាទីអីអត់?

ចឿង ៖ ទេ! អត់មានទេ ។

ធានី ៖ អត់ទេ អ៊ំអ្នកនេសាទដែរ?

ចឿង ៖ ហ្នឹងឯង ។

ធានី ៖ ហើយពួកគាត់ ពេលចឹងក្រៅពីការនេសាទមានធ្វើអីទៀតអត់?

ចឿង ៖ មិនដឹងទេ ។

ធានី ៖ អត់មានធ្វើអីទៀត ចឹងនេសាទពីពេលណាដល់ពេលណាទៅបានសម្រាក?

ចឿង ៖ បានត្រឹមម៉ាខែក្រហមនឹង ។

ធានី ៖ ចុះក្រៅពីការធ្វើម៉ាត្រឹមខំហ្នឹងហើយ គឺត្រឡប់មកផ្ទះយើងវិញចប់ហើយ?

ចឿង ៖ បាទ!

ធានី ៖ យើងនៅផ្ទះសម្រាកទៅ?

ចឿង ៖ បាទ!

ធានី ៖ ចឹងអ៊ំនៅផ្ទះ គ្រួសារអ៊ំនៅផ្ទះដែរ ឬមួយក៏ទៅប្រូតបាត់ៗ?

ចឿង ៖ ទេ! ធ្វើទាល់តែចប់យួនចូលមក យួនចូលមកចប់ ។

ធានី ៖ បាននៅជុំគ្នា?

ចឿង ៖ បាទ!

ធានី ៖ ចឹងកាលមុនបែកគ្នាដែរ?

ចឿង ៖ បែកគ្នា ។

ធានី ៖ ចុះពេលយួនចូលមករត់ទាំងអស់គ្នាអត់?

ចឿង ៖ រត់ ។

ធានី ៖ រត់ទៅណាវិញ?

ចឿង ៖ ខ្ញុំនែក! ដល់ពេលយួនចូលមក ខ្ញុំផ្លាស់ពីត្រង់នេះទៅនៅភូមិអូរនោះ ពីតាម៉េងទៅនៅភូមិអូរ លើកទំនប់ផង ទៅនៅធ្វើត្រីផង ។

ធានី ៖ ចឹងបានជួបគ្នាទៅក៏រត់ទាំងអស់គ្នាទៅ?

ធឿន ៖ ដល់យួនចូលមកត្រង់នេះមកនៅស្រុកវិញ ។

ធានី ៖ មកនៅស្រុកវិញ?

ធឿន ៖ បាទ!

ធានី ៖ មកនៅស្រុកវិញបានប៉ុន្មានថ្ងៃ បានគេថាយួនគេចាប់អីយកចង?

ធឿន ៖ អូ! យូរឆ្នាំ ម៉ាឆ្នាំនោះ ។

ប្រពន្ធ ៖ កាលនោះយូរគ្រាន់ នៅប្រហែលបានកន្លះខែៗនោះឯង ចាប់គា ។ ខ្ញុំនៅផ្ទះនៅដីនេះឯង មកចាប់នេះ ។

ធានី ៖ បន្ទាប់មកទៀតម៉េចទៀតអ៊ំ ក្រោយពីចាប់មកអីរស់នៅធម្មតា?

ធឿន ៖ ចា៎!

ធានី ៖ ចុះមាន គេថានៅដូចថាមានបន្ទាយ មានជំរំមានអីគេនោះ ខាងភ្នំឆ័ត្រអីមានជំរំដែរដូវនឹង ដែលអ្នកផ្សេងៗគេរត់មកតាំងពីក្នុងមក?

ប្រពន្ធ ៖ នៅតាមផ្ទះតាមអីនឹង ។

ធឿន ៖ អូ! អ្នកផ្សេងនៅតាមពួកខ្ញុំឯង ។ គ្នាសុំនៅតាមផ្ទះប្រជាជនមក ដែលនៅតាមយើងនេះឯង ។

ធានី ៖ ចុះដូចថាប្រជាជននឹង គាត់រត់ គាត់ចង់ទៅណា?

ធឿន ៖ ដល់យួនចូលមក គេយកទៅវិញអស់ ។

ធានី ៖ ចឹងកាលពេលសម័យប៉ុលពតនឹង ដែលឃើញប្រជាជនអ្នក១៧មេសាអីមកពីភ្នំពេញអីមានទេ?

ធឿន ៖ មានៗ ។

ប្រពន្ធ ៖ មានពីភ្នំពេញពីអីមក ។

ធានី ៖ ពេញនឹង?

ធឿន ៖ គេបញ្ជូនពីក្នុង មកយើងនេះឯង ។

ប្រពន្ធ ៖ គាត់ដើរហើមដៃ ហើមជើងអស់ គ្មានមិនមានអីស៊ី ខ្លះមានមាសហើយមិនដឹងធ្វើម៉េចធ្វើម៉េចបានអង្ករហូប ។

ធានី ៖ នៅផ្ទះអ៊ំមានប៉ុន្មាននាក់ទៅ?

ធឿន ៖ ផ្ទះខ្ញុំមានម៉ាគ្រួសារទេនោះ មាន២-៣នាក់ ។

ធានី ៖ ស្គាល់ឈ្មោះគាត់ទេ ដែលមកស្នាក់នៅជាមួយអ៊ំ?

ថឿន ៈ ទេ! មិនស្គាល់ទេ ។

ធានី ៈ ចុះគាត់ទៅណាអស់?

ថឿន ៈ ឈ្មោះនោះមួយ ប្ដីនោះពស់ចឹក ។

ធានី ៈ ឈ្មោះអីគេមិញ?

ថឿន ៈ ឈ្មោះ តានឹម ។ ។

ធានី ៈ តានឹម គាត់ស្លាប់ហើយ ដោយសារពស់ចឹក?

ថឿន ៈ ស្លាប់ហើយ ។

ធានី ៈ ចុះគ្រួសារគាត់?

ថឿន ៈ គ្រួសារនៅ ។

ប្រពន្ធ ៈ គ្រួសារនៅកូន២នាក់ គាត់ទៅវិញដែរ យួនចូល ។

ថឿន ៈ ដល់យួនចូលមិនដឹងទៅណាអស់ ។

ធានី ៈ អត់ដឹងទៅណាវិញអ៊ំនោះ?

ថឿន ៈ មិនដឹងទៅណា ដឹងភូមិណា ដឹងទៅស្រុកទៅស្រែ ដឹងទៅដល់ណាទេ ។

ធានី ៈ ចុះដូចថាអ្នកដែលដ្ឋីទាំងអស់នឹង ភាគច្រើនសម័យប៉ុលពតនឹងនៅរស់ច្រើនទេ?

ថឿន ៈ នៅរស់ច្រើនតើមានអី ។

ធានី ៈ ចុះអ៊ំថាអត់បាយ អត់អីនោះ?

ថឿន ៈ អត់បាយនោះនៅរស់តិច ងាប់ៗច្រើនដែរនោះ ។

ប្រពន្ធ ៈ ងាប់ច្រើន ខ្លះមានគេមកធ្វើបុណ្យកូនមានកូនងាប់ឆ្លៀតធ្វើបុណ្យ ដែលម៉ែងាប់ក៏កូនគេមកធ្វើបុណ្យ ។

ធានី ៈ មានច្រើនដែលនៅភូមិយើង?

ថឿន ៈ មាន២-៣នេះដែរ គេមកធ្វើបុណ្យបងប្អូនគេ ។

ធានី ៈ ហើយបន្ទាប់មកទៀតម៉េចអ៊ំដល់ពេល ហើយដល់មិញអ៊ំថាយួនចូលអីចឹងមក ហើយអ៊ំនៅនឹង ហើយមានអ្នកផ្សេងគេមកសុំនៅអីចឹង ។ តើមានទាហានគេវៃគ្នាទៀតអត់ពេលនឹង ពេលយួន ចូលមក?

ថឿន ៈ នៅបើកាលយួនចូលមកដល់ នឹងមកហួសមកនេះហើយ អូ!អានឹងវៃអស់ច្រើនណាស់ ខ្ញុំចាំបានតាមួយ តាខៀវ គាត់ថាចំណាំបាន៨៤ដង អឺ!៨៣ដង ។

ធានី ៈ ចំណាំបាន៨៣ដងម៉េច?

ថឿង ៖ នែក! ដែលបាញ់នៅភូមិនេះបាញ់យួន ខ្មែរក្រហមបាញ់យួននៅភូមិនេះ៨៣ដង ។

ធានី ៖ ៨៣ដងនឹងម៉េច មានន័យថាម៉េច មានន័យថា?

ថឿង ៖ ដែលបាញ់ម៉ាលើកចេះទៅ កន្លះខែ ម៉ាខែមកទៀត នៅពោកបាក់ក្នុងភូមិយើងនេះ៨៣ដង ។

ធានី ៖ ៨៣ដង?

ថឿង ៖ បាទ! ខ្ទាំងដាងគេភូមិយើង ម៉ាភូមិ ។

ធានី ៖ ចឹងអ៊ំនៅម៉េចកើតទៅ បើគេបាញ់គ្នាចឹង?

ថឿង ៖ ទេ! យូរៗគេបាញ់ម្ដងៗ ។

ប្រពន្ធ ៖ យូរៗបាញ់ម្ដងដីកត្រង់សេរ ។

ថឿង ៖ ដីកត្រង់សេរនៅទៅ ។

ធានី ៖ មានដីកទុកដែរ?

ប្រពន្ធ ៖ ដីកទុកគ្រប់តែគ្រួសារ ។

ថឿង ៖ ដីកគ្រប់គ្រួសារ ។

ប្រពន្ធ ៖ ខាងខ្ញុំ ត្រង់សេរខ្ញុំម៉ាល្មេដាក់ឈើតំរួច២-៣សារទៅ ក៏ដាក់ដីពីលើទៀត ។

ធានី ៖ ដល់ពេលក្រោយពីយួនអស់ទៅមានធ្វើអីទៀតអត់?

ថឿង ៖ អត់ទេ ប៉ុននោះ ។

ធានី ៖ អត់មានធ្វើអីទៀតទេ?

ថឿង ៖ ធ្វើតែស្រែ ។

ធានី ៖ នៅស្រុកភូមិយើង?

ថឿង ៖ ធ្វើស្រែ ។

ធានី ៖ ធ្វើស្រែធ្វើចំការធម្មតា?

ថឿង ៖ បាទ!

ធានី ៖ ចុះអ៊ំដែលធ្លាប់ឮស្គាល់ឈ្មោះឌុចទេ?

ថឿង ៖ អឺ! ឌុចនោះ ស្គាល់នោះឯង បើយើងនៅនេះហៅពិន ។

ធានី ៖ ហៅពិន?

ថឿង ៖ ហ្នឹងឯង ។

ធានី ៖ អូ!ហ្នឹងហើយតាពិន ។ ម៉េចបានស្គាល់គាត់ អ៊ំ?

ចឿន ៖ ធ្វើនៅនេះ គាត់ធ្វើគ្រូបង្រៀនៗហើយ នែក!ទិញបានជាម៉ាស៊ីនៗកិនស្រូវៗមួយដល់នេះ ធ្វើដុះទៅ ធ្វើគ្រូបង្រៀន ។

ធានី ៖ ហើយម៉េចទៀតទៅ?

ចឿន ៖ បើយើងនៅនេះ គាត់ស្លូតណាស់ បើយើងនៅនេះហៅតែតាពិនៗ ។ អត់ដឹងថាគាត់ចាប់ណា នៅនេះអត់មានអ្នកណាដឹងអីទេ សុភាពទៅណា ។

ធានី ៖ ចុះអ៊ំដឹងថាតាពិន ពីមុនមកគាត់ធ្វើអីៗទេ ដំបូងដែលគាត់?

ចឿន ៖ អត់ទេ អត់ចេះ គិចគាត់ថាមកនៅថាខ្មែរក្រហម ព្រោះស្រុកយើងនេះមានខ្មែរក្រហមច្រើនដែរនឹង ។

ធានី ៖ អូ! ស្រុកយើងនេះមាន?

ចឿន ៖ មាន ប៉ុន្តែគេ ។

ធានី ៖ គេដឹង?

ចឿន ៖ មិនដឹងយ៉ាងណា៎ ។

ធានី ៖ តែអ៊ំអត់ដឹងថាគាត់ធ្វើខ្មែរក្រហម?

ចឿន ៖ គ្រាន់តែឃើញគាត់ធ្វើខ្មែរក្រហមនោះ ក៏ដល់មកបូកប៉ាក់នឹងគ្នាខ្មែរក្រហមគ្នាគេរហូត ។ ប៉ុន គាត់មកនៅនេះ នាំគ្នាគ្មានថាអីធ្វើអីទេ ។

ធានី ៖ ចុះអ៊ំខ្មែរក្រហមយើងនៅនេះ អ្នកណាអ្នកគ្រប់គ្រង អ្នកធំនៅនេះ?

ចឿន ៖ គ្មានទេ ។

ធានី ៖ អត់មាន សុទ្ធតែអ្នកតូចៗ?

ចឿន ៖ អ្នកតូចៗ ។

ធានី ៖ រួចពីជំរំ?

ចឿន ៖ នោះហើយ កូនទាហាន ។

ប្រពន្ធ ៖ ស្រុកយើងនេះក៏ដូចថា ខ្មែរក្រហមគេមកដូចថាខ្មែរក្រហមគេមក គេស្គាល់គ្នាខ្ញុំក៏ស្គាល់មិត្ត ឯងៗថាតស់ទៅលេងចេះចុះទៅក៏ទៅលេងនឹងគេ ។

ធានី ៖ ជាពិសេសគេអត់ដឹង?

ប្រពន្ធ ៖ នោះឯង អ្នកគេអត់ដឹងទេ ។

ធានី ៖ ប៉ុន្តែខ្មែរក្រហមនឹង គេស្គាល់តាពិននឹង?

ចឿន ៖ ហ្នឹងឯង ស្គាល់ នៅជាមួយគ្នា ដល់មកស្គាល់គ្នា យកកូនចៅមកនៅទៅ ។

ធានី ៖ ឆ្នាំប៉ុន្មានកាលនឹង?

ថឿង ៖ អូ! អត់បានចាំទេ ។

ប្រពន្ធ ៖ គាត់ធ្វើស្រែ គាត់ទិញស្រែ ទិញដីធ្វើផ្ទះធ្វើអី នៅទិញម៉ាស៊ីនកិនស្រូវកិនអីអាកូនម៉ាស៊ីនតូចនឹង គ្មានអ្នកណាដឹងថាគាត់ចុះៗ ។

ថឿង ៖ នឹកគាត់ធ្វើអី មិនដឹងស្អីណា ។

ប្រពន្ធ ៖ ដឹងថាប្រពន្ធគាត់ មិនដឹងម៉េចបានប្រពន្ធគាត់ មិនដឹងម៉េច ត្រូវងាប់ប្រពន្ធគាត់ ។

ថឿង ៖ ចុះគេចាក់ គេប្ងន់ៗគាត់ចាក់គាពិនត្រូវដែរប៉ុនត្រូវវាមិនងាប់ ប៉ុនថាប្រពន្ធនេះវាចំអាស្បែក មុត ។

ធានី ៖ បន្ទាប់មកទៀត ម៉េចទៀតអ៊ំ ចឹងអ៊ំក្រោពីនឹងអ៊ំរាល់ថ្ងៃ អ៊ំរស់នៅធ្វើស្រែចំការធ្វើអីដែរឬក៏ យ៉ាងម៉េច?

ថឿង ៖ ហ្នឹងសព្វថ្ងៃធ្វើចំការរហូតមក ។

ធានី ៖ ធ្វើរហូតមកដល់ឥឡូវ?

ថឿង ៖ នៅៗសព្វថ្ងៃនេះ ។

ធានី ៖ ហើយកូនចៅអីជួយអ៊ំរកស៊ី ធ្វើស្រែចំការអីដែរ?

ប្រពន្ធ ៖ ធ្វើកូននៅៗលីវ ស្រី២ ប្រុស១ ធ្វើស្រែអស់ ។

ធានី ៖ ចឹងអ៊ំមានអីចង់សួរខ្ញុំវិញទេ សួរម៉ាថ្ងៃហើយ?

ថឿង ៖ មានទៅសួររឿងអី ។

ធានី ៖ ចាំ!អត់មានអ៊ំ?

ថឿង ៖ បាទ!

ធានី ៖ អរគុណច្រើនអ៊ំណា ។

«ចប់»